01172165

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 11 / 2015
ម៉ោង (Time/Heure) : 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E349/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥

**ជូនចំពោះ៖** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យមានការវាយតម្លៃដោយអ្នកជំនាញលើឯកសារ E3/2107

1. កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយពីមេធាវីការពារក្តី ខៀវ សំផន ("សំណើ") ស្នើសុំឱ្យមានការវាយតម្លៃដោយអ្នកជំនាញលើអក្សរសរសេរដោយដៃនៃឯកសារ E3/2107 (ឯកសារ E349 កថាខណ្ឌ ៣-៤, ២៨)។ ពុំមានភាគីណាមួយឆ្លើយតបទៅនឹងសំណើសុំនេះទេ។

2. មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងយថាភាពនៃឯកសារ E3/2107 ដោយអះអាងថា វាជារបាយការណ៍គ្មានកាលបរិច្ឆេទ ដែល តា អាន ផ្ញើទៅគណៈស្រុកត្រាំកក់ បរិយាយពីចំនួនមនុស្សដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ("ឯកសារ")(ឯកសារ E349 កថាខណ្ឌ ២)។ មេធាវីការពារក្តីអះអាងថា ឯកសារដែលសហព្រះរាជអាជ្ញាទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានសារៈសំខាន់យ៉ាងខ្លាំងចំពោះសំណុំរឿង ០០២/០២ ដោយសារតែឯកសារនេះមានការជាប់ពាក់ព័ន្ធនៅក្នុង

ដីកាដំណោះស្រាយជាច្រើនផង (ឯកសារ E349 កថាខណ្ឌ ៥-៧)។ មេធាវីការពារក្តីអះអាងថា ឯកសារនោះជាឯកសារក្លែងក្លាយ ដោយមានកត់សម្គាល់ទៅលើចំណុចមួយចំនួន៖ វត្តមាននៃសំណេរដោយដៃនៅលើក្រដាសដាច់ដោយឡែកពីគ្នា, អក្សរដែលសរសេរដោយដៃនៅលើឯកសារ គឺមានលក្ខណៈខុសៗគ្នា, ការខកខានរបស់សាក្សី ពេជ្រ ជីម និង ស្រី ថន ក្នុងការកំណត់ថាជាហត្ថលេខារបស់ តា អាន នៅលើសំណេរនោះ, ភាពមិនស៊ីសង្វាក់គ្នាមួយចំនួននៅក្នុងឯកសារ និង អត្ថិភាពនៃកំណត់ហេតុក្លែងក្លាយ និងក្លែងបន្លំជាទូទៅនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ (ឯកសារ E349 កថាខណ្ឌ ៧-១១)។ ចុងក្រោយ មេធាវីការពារក្តីអះអាងថា ឯកសារ និង សក្ខីកម្មផ្សេងៗទៀត ខុសគ្នាពីតួលេខនៃចំនួនមនុស្សស្លាប់នៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលបានយោងនៅក្នុងឯកសារ (ឯកសារ E349 កថាខណ្ឌ ១២-២៧)។

3. ជាបញ្ហាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា សំណើនេះដាក់ជូននៅក្នុងពេលវេលាមួយមិនសមស្រប។ ឯកសារនោះគឺជាផ្នែកនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបានដាក់នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៧ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ១៨.៤) ហើយសំណៅបកប្រែជាភាសាអង់គ្លេស បានដាក់នៅក្នុងខែ មីនា ឆ្នាំ ២០០៩ និង សំណៅបកប្រែជាភាសាបារាំង បានដាក់នៅក្នុងខែ មីនា ឆ្នាំ ២០១១។ សហចៅក្រមស៊ើបអង្កេតបានយោងទៅលើឯកសារនោះនៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២ (ឯកសារ D427 ជើងទំព័រ ២១៧៣, ២២២១)។ លើសពីនេះទៀត ឯកសារនោះត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញានៅក្នុងបញ្ជីឯកសារដំបូងរបស់ខ្លួន នៅក្នុងខែ មេសា ឆ្នាំ ២០១១ (ឯកសារ E9/31.8 ទំព័រ ៣) ដែលមេធាវីការពារក្តី ខៀវ សំផន មានឱកាសក្នុងការឆ្លើយតបទៅនឹងការស្នើឡើងនោះ មុនពេលឯកសារនោះត្រូវបានអង្គជំនុំជម្រះទទួលយកនៅក្នុង ខែ ធ្នូ ឆ្នាំ ២០១២ (ឯកសារ E185/1.3 ទំព័រ ២៧)។ ហេតុដូច្នេះ មេធាវីការពារក្តី ខៀវ សំផន មិនបានប្រើប្រាស់ឱកាសយ៉ាងច្រើននេះដើម្បីលើកនូវបញ្ហានេះជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះសាលាដំបូងឡើយ ប៉ុន្តែបែរជារង់ចាំរហូតដល់អង្គជំនុំជម្រះសាលាដំបូងជិតបញ្ចប់ការសួរដេញដោលទៅលើភ័ស្តុតាងពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ ទើបលើកបញ្ហានេះឡើង។ ការដាក់សំណើនៅនាទីចុងក្រោយបែបនេះ អាចបង្កឱ្យមានការពន្យារកិច្ចដំណើរការនីតិវិធី និង ប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និង ឆាប់-រហ័ស (ច្បាប់ អ.វ.ត.ក មាត្រា ៣៣ថ្មី)។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា វាគឺជាប្រយោជន៍យុត្តិធម៌ក្នុងការវាយតម្លៃលើខ្លឹមសារនៃសំណើនេះ។

4. អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា រួមទាំងបង្គាប់ឱ្យធ្វើកោសលវិច័យ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង

យល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់។ លើសពីនេះទៀត វិធាន ៣១ នៃវិធានផ្ទៃក្នុង ចែងថា អង្គ-ជំនុំជម្រះអាចស្វែងរកជំនួយជាមតិយោបល់ពីអ្នកជំនាញអំពី “បញ្ហាដែលយល់ឃើញថាមានសារៈសំខាន់ចាំបាច់ដល់ការស៊ើបសួរ ឬ កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក”។ តួនាទីរបស់អ្នកជំនាញ គឺដើម្បីជួយបំភ្លឺដល់អង្គជំនុំជម្រះលើបញ្ហាបច្ចេកទេសជាក់លាក់ផ្សេងៗ ដែលទាមទារនូវចំណេះដឹងពិសេសនៅក្នុងវិស័យជាក់លាក់មួយ (ឯកសារ E215 កថាខណ្ឌ ១៦)។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងស្នើសុំមតិ-យោបល់ពីអ្នកជំនាញ អនុលោមតាមខ្លឹមសារនៃវិធាន ៣១ និង វិធាន ៩៣ នៃវិធានផ្ទៃក្នុង តែក្នុងករណីដែលកោសលវិច័យនោះមានសារៈសំខាន់ជួយដល់អង្គជំនុំជម្រះនៅក្នុងការសម្រេចទៅលើបញ្ហានានាដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ប៉ុណ្ណោះ។

5. អង្គជំនុំជម្រះកត់សម្គាល់ថា សំណៅឯកសារដែលមាននៅពេលបច្ចុប្បន្ននេះ គឺជាសំណៅថតចម្លងដែលបានមកពីពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយសារតែសំណៅដើមមិនទាន់ត្រូវបានរកឃើញនៅឡើយ (ឯកសារ E3/188 ទំព័រ ៤-៥)។ យ៉ាងហោចណាស់ ប្រការនេះរារាំងមិនអាចឱ្យធ្វើការប្រៀបធៀបអក្សរសរសេរដោយដៃពិតប្រាកដបានឡើយ និង បង្កើតនូវឧបសគ្គយ៉ាងខ្លាំងដល់ការវិភាគតាមបែបកោ-សល្យវិច័យឱ្យបានត្រឹមត្រូវ ដែលកាលៈទេសៈនេះ អាចត្រូវបានចាត់ទុកថា មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង (វិធាន ៨៧(៣)(គ))។

6. នៅគ្រប់ករណីទាំងអស់ អង្គជំនុំជម្រះយល់ឃើញថា វាមិនចាំបាច់ក្នុងការបង្គាប់ឱ្យមានការវាយតម្លៃដោយអ្នកជំនាញលើអក្សរសរសេរដោយដៃនៃឯកសារនោះឡើយ។ នៅក្នុងកាលៈទេសៈនេះ ការវាយតម្លៃថាតើ សំណេរនោះត្រូវបានសរសេរដោយមនុស្សម្នាក់ផ្សេងទៀតទៅលើផ្នែកនានានៃឯកសារនោះ និង /ឬថាតើ សំណេរនោះត្រូវបានសរសេរដោយមនុស្សពីរនាក់ផ្សេងគ្នា ឬ យ៉ាងណានោះ មិនតម្រូវឱ្យមានជំនួយពីអ្នកជំនាញឡើយ។ តាមពិត សាក្សីពីរនាក់ដែលពាក់ព័ន្ធ ហើយយល់ដឹងអំពីឯកសារនាសម័យកាលនោះ គឺ ពេជ្រ ជីម និង ស្រី ថន បានផ្តល់សក្ខីកម្មលើបញ្ហានេះរួចហើយ (ប្រតិចារឹក ថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០១៥ ទំព័រ ១០-១១ (ភាសាអង់គ្លេស), ប្រតិចារឹក ថ្ងៃទី ២៤ កុម្ភៈ ឆ្នាំ ២០១៥ ទំព័រ ៤១-៤២ (ភាសាអង់គ្លេស))។ គួរឱ្យកត់សម្គាល់ផងដែរថា ការបកប្រែឯកសារនោះពីភាសាអង់គ្លេសមានពាក្យពេចន៍ដូចខាងក្រោមនេះ៖ “*នៅទំព័រដាច់ដោយឡែកមួយដែលជាសំណេរសរសេរឡើក ខុសពីសំណៅអក្សរសរសេរដោយដៃផ្សេងទៀត*” (ឯកសារ E3/2107, ERN 00290205)។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះនឹងអាចធ្វើការសម្រេចដោយខ្លួនឯង ទាក់ទិននឹងយថាភាពនៃឯកសារនោះ ដោយមិនចាំបាច់មានជំនួយពីអ្នកជំនាញឡើយ។

7. មេធាវីការពារក្ដី ខៀវ សំផន ក៏បានលើកទឡ្ហីករណ៍ដែលសំដៅទៅដល់ទម្ងន់ និង តម្លៃជាភ័ស្ដុតាងនៃឯកសារនោះផងដែរ ជាពិសេស ទាក់ទិននឹងភាពត្រឹមត្រូវនៃតួលេខមនុស្សស្លាប់ចំនួន ១៥.០០០ នាក់ នៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ និង ភាពមិនស៊ីសង្វាក់គ្នា ទាក់ទិននឹងសក្ខីកម្មរបស់សាក្សី កែវ ច័ន្ទតារា និង ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន។ ទាំងនេះ គឺជាបញ្ហាដែលតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណានៅក្នុងអំឡុងនៃការពិភាក្សារបស់អង្គជំនុំជម្រះទៅលើអង្គហេតុនានា រួមទាំងការចោទប្រកាន់អំពីការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ហើយវាមិនចាំបាច់តម្រូវឱ្យមានការវាយតម្លៃដោយអ្នកជំនាញលើអក្សរសរសេរដោយដៃ ដូចដែលបានស្នើឡើងនោះទេ។

8. យោងទៅលើហេតុផលខាងលើ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្ដី ខៀវ សំផន ពុំបានបង្ហាញថា វាជាការចាំបាច់ក្នុងការបង្គាប់ឱ្យមានការវាយតម្លៃដោយអ្នកជំនាញលើអក្សរសរសេរដោយដៃនៃឯកសារនោះឡើយ (ឯកសារ E3/2107) អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ហើយអង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើនេះ។

9. នេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងឯកសារ E349។